ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២៩-៧-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៧០៩/៧៥៨ ស្តីពីការប្រោសព្រះរាជទាន ចំពោះឯកឧត្តម **សុខុម គគចន្ទមុន្នី** នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ៥៥៤៨

២៩-៧-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៧០៩/៧៥៩ ស្តីពីការតម្លើងឋានៈជូនអគ្គលេខាធិការរង នៃ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ចំនួន ០៤ រូប និង តែងតាំងឯកឧត្តម **ឆាយ ឆត្រាខុធ** ជា អគ្គលេខាធិការរង នៃ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល មានឋានៈស្មើ អគ្គនាយក ៥៥៤៩

២៩-៧-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៧០៩/៧៦០ ស្តីពីការតែងតាំងសមាសភាពថ្នាក់ដឹកនាំ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ចំនួន ០៤ រូប ៥៥៥០

០១-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៧៦១ ស្តីពីការតែងតាំងលោក **ឌឹម ខុឌ្ឍីរិទ្ធិ** និងលោក **សៀ ឫទ្ធិ** ជា ឧកញ៉ា ៥៥៥២

០១-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៧៦៥ ស្តីពីការដាក់ឱ្យមន្ត្រីរាជការចូលនិវត្តន៍ក្នុងក្របខ័ណ្ឌ មន្ត្រីការទូតជាន់ខ្ពស់ ចំនួន០៤ រូប ដោយរក្សាមុខតំណែងដដែល ៥៥៥៣

០១-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៧៦៩ ស្តីពីការតែងតាំងសមាសភាព នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ចំនួន ១២ រូប ៥៥៥៥

០១-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៧៧០ ស្តីពីការប្រោសព្រះរាជទាន ចំពោះឯកឧត្តម **ស៊ីម ខណ្ណា** នូវគ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ស៊ីសុវត្ថិមុនីវង្ស កុសមៈនារីរ័ត្ន** ថ្នាក់ មហាសេនា ៥៥៥៧

០១-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៧៧១ ស្តីពីការប្រោសព្រះរាជទាន ចំពោះលោក **ហ៊ិច សុខណ្ណ** នូវគ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ ៥៥៥៨

០១-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៧៧២ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម.អ្នកស្រី និង អស់លោក ចំនួន ០៦ រូប ៥៥៥៩

០១-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៧៧៣ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម.លោកជំទាវ និង អស់លោក ចំនួន ០៩ រូប ៥៥៦០

០១-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៧៧៤ ស្តីពីការតែងតាំងឯកឧត្តម សុត ស៊ីនាន់ណា ជាទីប្រឹក្សារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី ៥៥៦១

០១-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៧៧៧ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ នាយទាហាន ចំនួន ២១ រូប ៥៥៦២

០១-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៧៧៨ ស្តីពីការប្រោសព្រះរាជទាន ចំពោះលោក អ៊ួច អនុត្តរោ នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ៥៥៦៣

## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

២៨-៧-២០០៩ -អនុក្រឹត្យលេខ ១១៣ អនក្រ.បក ស្តីពីការបង្កើតក្រុមការងារកំណែទម្រង់រដ្ឋបាល នៅតាមក្រសួង ស្ថាប័ន ៥៥៦៤

២៩-៧-២០០៩ -អនុក្រឹត្យលេខ ១១៤ អនក្រ.បក ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិអេស្កាប់ ៥៥៦៨

៣០-៧-២០០៩ -អនុក្រឹត្យលេខ ១១៥ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៥៥៧៦

៣០-៧-២០០៩ -អនុក្រឹត្យលេខ ១១៦ អនក្រ.បក ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប ៥៥៧៨

៣១-៧-២០០៩ -អនុក្រឹត្យលេខ ១១៧ អនក្រ.បក ស្តីពីការបន្ថែមប្រៀវត្សជូន ជនពិការ និវត្តជន និង ជនបាត់បង់សមត្ថភាពការងារ ៥៥៨៣

៣១-៧-២០០៩ -អនុក្រឹត្យលេខ ១១៨ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៥៥៨៥

៣១-៧-២០០៩ -អនុក្រឹត្យលេខ ១១៩ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៥៥៨៧

០៤-៨-២០០៩ -អនុក្រឹត្យលេខ ១២០ អនក្រ.បក ស្តីពីការធ្វើអនុបយោគ ផ្ទៃដីទំហំ ៥.០០០ ហិកតា ស្ថិតក្នុងដែនជម្រកសត្វព្រៃស្នួល ស្រុកកែវសីមា ខេត្តមណ្ឌលគិរី ៥៥៨៩

០៣-៧-២០០៩ -អនុក្រឹត្យលេខ ១១៦៨ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៥៥៩១

០៧-៧-២០០៩ -អនុក្រឹត្យលេខ ១១៦៩ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និង តែងតាំងមុខតំណែង នាយនគរបាលជាតិ ៥៥៩៣

០៧-៧-២០០៩ -អនុក្រឹត្យលេខ ១១៧០ អនក្រ.តត ស្តីពីការតែងតាំងមុខងារ នាយទាហាន ៥៥៩៤

០៧-៧-២០០៩ -អនុក្រឹត្យលេខ ១១៧១ អនក្រ.តត ស្តីពីការបញ្ចូលក្របខ័ណ្ឌ និង ប្រគល់ឋានន្តរស័ក្តិ នាយទាហាន ៥៥៩៥

០៧-៧-២០០៩ -អនុក្រឹត្យលេខ ១១៧២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៥៩៦
០៧-៧-២០០៩ -អនុក្រឹត្យលេខ ១១៧៣ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៥៥៩៧
០៧-៧-២០០៩ -អនុក្រឹត្យលេខ ១១៧៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការក្រសួងសាធារណការ និងដឹកជញ្ជូន ៥៥៩៨
០៧-៧-២០០៩ -អនុក្រឹត្យលេខ ១១៧៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៥៩៩
០៧-៧-២០០៩ -អនុក្រឹត្យលេខ ១១៧៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៦០០
០៧-៧-២០០៩ -អនុក្រឹត្យលេខ ១១៧៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៦០១
០៧-៧-២០០៩ -អនុក្រឹត្យលេខ ១១៧៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៦០២
០៧-៧-២០០៩ -អនុក្រឹត្យលេខ ១១៧៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៦០៣
០៧-៧-២០០៩ -អនុក្រឹត្យលេខ ១១៨០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៦០៤
០៧-៧-២០០៩ -អនុក្រឹត្យលេខ ១១៨១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៦០៥
០៧-៧-២០០៩ -អនុក្រឹត្យលេខ ១១៨២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៦០៦
០៧-៧-២០០៩ -អនុក្រឹត្យលេខ ១១៨៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៦០៧
០៧-៧-២០០៩ -អនុក្រឹត្យលេខ ១១៨៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៦០៨
០៧-៧-២០០៩ -អនុក្រឹត្យលេខ ១១៨៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៦០៩
០៧-៧-២០០៩ -អនុក្រឹត្យលេខ ១១៨៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៦១០
០៧-៧-២០០៩ -អនុក្រឹត្យលេខ ១១៨៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៦១១
០៧-៧-២០០៩ -អនុក្រឹត្យលេខ ១១៨៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៦១២
០៧-៧-២០០៩ -អនុក្រឹត្យលេខ ១១៨៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៦១៣
០៧-៧-២០០៩ -អនុក្រឹត្យលេខ ១១៩០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៦១៤
០៧-៧-២០០៩ -អនុក្រឹត្យលេខ ១១៩១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៦១៥
០៧-៧-២០០៩ -អនុក្រឹត្យលេខ ១១៩២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៦១៦
០៧-៧-២០០៩ -អនុក្រឹត្យលេខ ១១៩៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៦១៧
០៧-៧-២០០៩ -អនុក្រឹត្យលេខ ១១៩៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៦១៨
០៧-៧-២០០៩ -អនុក្រឹត្យលេខ ១១៩៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៦១៩
០៧-៧-២០០៩ -អនុក្រឹត្យលេខ ១១៩៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៦២០

## ២.សេចក្តីសំរេច

៣១-៧-២០០៩ -សេចក្តីសំរេចលេខ ៤៨ សសរ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសម្របសម្រួល រៀបចំ និង អនុវត្តគម្រោងអភិវឌ្ឍន៍នៅតាមបណ្តោយព្រំដែនទិសខាងលិច និង ខាងជើង នៃព្រះរាជាណាចក្រកម្ពុជា ៥៦២២

## III.ការិយាល័យក្រសួង

### ១.ទីស្តីការរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

២៨-៧-២០០៩ -ប្រកាសលេខ ៧៣៤ ស.អ.យ ស្តីពីការគ្រប់គ្រង ការរៀបចំរចនាសម្ព័ន្ធចាត់តាំង និង ការប្រព្រឹត្តទៅ របស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ៥៦២៦

២៨-៧-២០០៩ -ប្រកាសលេខ ៧៣៥ ស.អ.យ ស្តីពីការបង្កើតរូបសញ្ញារបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់ មន្ត្រីរាជការស៊ីវិល ៥៦៣២

### ២. ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៧-១១-២០០៨ -លិខិតបញ្ជាក់លេខ ៥៩១៦ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គ្រួសារ អាប៉ែល ខូ អិលធីឌី** ៥៦៣៥

០៧-១១-២០០៨ -លិខិតបញ្ជាក់លេខ ៥៩១៨ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដ៉ោ យូ អេនធើប្រាយស៍** ៥៦៣៧

០៧-១១-២០០៨ -លិខិតបញ្ជាក់លេខ ៥៩៣៤ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មេគង្គ ម៉ាឃីត អិលធីឌី** ៥៦៣៩

០៧-១១-២០០៨ -លិខិតបញ្ជាក់លេខ ៥៩៣៥ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់សាខាក្រុមហ៊ុន **អ៊ិនធីគ្រេតសិន ហ្វាយនែន គ្រុប ខបភើរេសិន** ៥៦៤១

០៧-១១-២០០៨ -លិខិតបញ្ជាក់លេខ ៥៩៣៦ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប៊ី & គី គ្រុប (ខេមបូឌា)** ៥៦៤២

០៧-១១-២០០៨ -លិខិតបញ្ជាក់លេខ ៥៩៣៨ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ូ ហ្វូ ខមភេនី លីមីធីត** ៥៦៤៤

០៧-១១-២០០៨ -លិខិតបញ្ជាក់លេខ ៥៩៤០ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប្រាយ ស៊ី អ៊ិនវេសមេន** ៥៦៤៦

០៧-១១-២០០៨ -លិខិតបញ្ជាក់លេខ ៥៩៤១ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់សាខាក្រុមហ៊ុន **ប៊ុមយ៉ាង អ៊ែរ ខនឌីសិននីង** ៥៦៤៨

០៧-១១-២០០៨ -លិខិតបញ្ជាក់លេខ ៥៩៤២ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ី.អាណា ខូ អិលធីឌី** ៥៦៥០

០៧-១១-២០០៨ -លិខិតបញ្ជាក់លេខ ៥៩៤៥ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **តាសស្ទាន់ ម៉ូធ័រ (ខេមបូឌា) ខូ អិលធីឌី** ៥៦៥២

# ព្រះរាជក្រឹត្យ

នស/រកត/០៧០៩/៧៥៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម សុខុម ភគវន្តមុនី

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

៣រល.០៩០៧.៧៦៩

ព្រះហស្តលេខា និងព្រះរាជលញ្ចករ
នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៩* លេខៈ ៧០៤ ច.ល

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល

យ៉ុន ជីនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៧០៩/៧៥៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកត / ០៩០៤ / ២៨៤ ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានតម្លើងឋានៈជូនអគ្គលេខាធិការរង នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលចំនួន ០៤រូប ដូចមានរាយនាមខាងក្រោម ÷

១. ឯកឧត្តម **ហង្ស ឆាំឆាន** មានឋានៈស្មើ **រដ្ឋលេខាធិការ**
២. ឯកឧត្តម **ឈួន ឆាម** មានឋានៈស្មើ **រដ្ឋលេខាធិការ**
៣. ឯកឧត្តម **ប៉ូល ពីឡូ** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**
៤. លោកជំទាវ **នាង លីណា** មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**។

**មាត្រា ២** : ត្រូវបានតែងតាំងឯកឧត្តម **ឆាយ ឆត្រាខុធ** ជាអគ្គលេខាធិការរងក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលមានឋានៈស្មើ **អគ្គនាយក**។

**មាត្រា ៣** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៤** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៥** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.០៩០៧.៧៧០

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៩*

លេខ ៧០៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០០៩
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៧០៩/៧៦០

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/៣៤៨ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា១ និងមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងសមាសភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ដូចមានរាយនាមខាងក្រោម៖

១. ឯកឧត្តម **ស៊ុយ ម៉ុងឈាង** ជាអគ្គលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
២. ឯកឧត្តម **សួង លាងហៃ** ជាអគ្គលេខាធិការរង មានឋានៈស្មើ **រដ្ឋលេខាធិការ**
៣. ឯកឧត្តម **ម៉ែន ប៊ុនឈា** ជាអគ្គលេខាធិការរង មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**

៤. ឯកឧត្តម **បួន សុមុនី** ជាអគ្គលេខាធិការរង មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបាន សម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

*៣៩៧.០៩០៧.៧៧១*

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩*

លេខៈ ៧០១ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០០៩
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧៦១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា**
**សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

## តែងតាំង

**១-លោក ឱម ចុឡារិទ្ធិ**
**២-លោក សៀ ឫទ្ធី**

**ជា**

## ឧកញ៉ា

៣រល.០៩០៩.៧៧២

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៩*

លេខៈ ៩៩១៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ៧ ឆ្នាំ២០០៩
រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧៦៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១.-**

ត្រូវបានដាក់ឱ្យមន្ត្រីរាជការចូលនិវត្តន៍ក្នុងក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ដោយរក្សាមុខតំណែងដដែល ដូចមានរាយនាមខាងក្រោម ÷

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

១-ឯកឧត្តម **ឆុង ទីន** ឯកអគ្គរាជទូតប្រចាំប្រទេសគូបា ឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៤

២-លោកជំទាវ **យូ អយ** ឯកអគ្គរាជទូតប្រចាំប្រទេសថៃឡង់ដ៍ ឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ១

៣-ឯកឧត្តម **ជាង អេងងួន** អគ្គលេខាធិការរងរាជរដ្ឋាភិបាល ឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ១

៤-ឯកឧត្តម **រស់ គង់** អគ្គលេខាធិការរងគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ឧត្តមមន្ត្រីការបរទេស ថ្នាក់លេខ ៤ ។

**មាត្រា២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៥ល.០៩០៧.៧៧៦

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៩*

លេខ : ៧២១ .ច.ល

[illegible]ផ្ញើច្បាប់ចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សី'ហ ឆ្នាំ២០០៩

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ស៊ុំ ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧៦៩

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/៣៤៨ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា១ និងមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានតែងតាំងសមាសភាព នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ចំនួន ១២រូបដូចមានរាយនាម ខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **សុខ អាន** | ឧបនាយករដ្ឋមន្ត្រី<br>រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សហប្រធាន |
| ២. ឯកឧត្តម **ឌិត មុន្ទី** | ប្រធានតុលាការកំពូល | សហប្រធាន |
| ៣. ឯកឧត្តម **អង្គ វង្ស វឌ្ឍានា** | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធាន |

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

| | | |
|---|---|---|
| ៤. ឯកឧត្តម **ឱម យ៉ិនទៀង** | ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយ | អនុប្រធាន |
| ៥. ឯកឧត្តម **យូ ប៊ុនឡេង** | ប្រធានសាលាឧទ្ធរណ៍ | អនុប្រធាន |
| ៦. ឯកឧត្តម **ជីវ កេង** | ប្រធានសាលាដំបូងរាជធានីភ្នំពេញ | សមាជិក |
| ៧. លោកជំទាវ **លី ឆួចឡេង** | តំណាងក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ៨. ឯកឧត្តម **អ៊ុក រ៉ាប៊ុន** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៩. ឯកឧត្តម **សុក ផេង** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១០. ឯកឧត្តម **នុត សាអាន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១១. ឯកឧត្តម **គឹម ស៊ីថន** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១២. ឯកឧត្តម **ស៊ុយ ម៉ុងលាង** | អគ្គលេខាធិការ នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ | សមាជិកអចិន្ត្រៃយ៍។ |

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ពរល.០៨០៩.៧៩០

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៩*

លេខៈ ៧១៤ .ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០០៩

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧៧០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម ស៊ឹម វណ្ណា

នូវ

គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រិយានី ស៊ីសុវត្ថិមុនីវង្ស
កុសុមៈនារីរត្ន ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចរល.០៩០៩.៧៩១

លេខ: ៩២០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ម៉ៅ ជិនកេន

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៩*

ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧៧១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

-លោក ហ៊ីង សុវណ្ណ

នូវ

គ្រឿងឥស្សរិយយសសុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍

ព្រះហស្តលេខា និងព្រះរាជលញ្ចករ
នរោត្តម សីហមុនី

៣រល.០៩០៩.៧៤៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៩

លេខ: ៧១៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧៧៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ជូន

ក- គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

ឯកឧត្តម លី ឆេង

ខ- គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

អ្នកស្រី ឈុន ផាណ្ណា

គ- គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :

១- លោក ឈឹម សំណាង

២- លោក ឃុន សុភាព

៣- លោក យេង លាងហ៊ី

ឃ- គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ :

លោក ម៉ម ហ៊ីណង់

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

លេខ: ៧១៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

ពរល.០៨០៩.៧៤៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៩

នស/រកត/០៨០៩/៧៧៣

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

## ប្រោសព្រះរាជទាន

**នូវ**

ក_គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :
-ឯកឧត្តម ហោ សុធន

ខ_គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :
១-ឯកឧត្តម កៅ គីមហ៊ួន
២-ឯកឧត្តម ហ៊ុល ផានី

គ_គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :
-ឯកឧត្តម កុយ គួង

ឃ_គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សរឫទ្ធិ ចំពោះ :
១-លោកជំទាវ អ៊ិត សោភា
២-លោកជំទាវ ឡូច ផានី
៣-ឯកឧត្តម តូច កែម៉ារី

ង_គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ :
១-លោក នួន ជីវន្ត
២-លោក ថៃ វណ្ណា

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.០៩០៧.៧៩៤

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៩*

លេខៈ ៧៦៤ ច.ល
ថតចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧៧៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងឯកឧត្តម **សុក ស៊ីផាន់ណា** ជាទីប្រឹក្សារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៦៧.០៩០៨.៧៩៥

លេខៈ ៥១៩ ច.ល

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៩*

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ៧ ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ជីនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧៧៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

## ត្រាស់ព្រះរាជប្រទាន

នូវ

**ក : គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំនួន ១៣ រូប :**

១- លោក រីន ស៊ីថា
២- លោកស្រីវរសេនីយ៍ទោ លឹម សុវណ្ណា ០៤៤៥៦
៣- លោកវរសេនីយ៍ទោ ហាស់ ម៉េងហួត ៣០៦៩៩
៤- លោកវរសេនីយ៍ត្រី ហុង ដារ៉ារេត ០៨៤៥៨
៥- លោកវរសេនីយ៍ត្រី សោម វុទ្ធី ០៣០១២
៦- លោកវរសេនីយ៍ត្រី ខាត់ សុខ ០៨៣៧៣
៧- លោកវរសេនីយ៍ត្រី ម៉ា ញ៉ែម ០៧២៣៧
៨- លោកវរសេនីយ៍ត្រី ខាំផែន ច័ន្ទវត្តី ០៣០៣៣
៩- លោកវរសេនីយ៍ត្រី ប្រាក់ វុត្ថា ០៥៦៧៩
១០- លោកវរសេនីយ៍ត្រី ឡុង សំណាង ១២២៧៣
១១- លោកវរសេនីយ៍ត្រី ចាន់ សារិន ០៣៣១០
១២- លោកវរសេនីយ៍ត្រី ម៉ុយ ជៀង ០៣០១៣
១៣- លោកវរសេនីយ៍ត្រី ទឹម សិលា ០៧២៧៣

**ខ : គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំនួន ០៨ រូប :**

១- លោកអនុសេនីយ៍ឯក ផុល ថូ ២៨៨៧៦
២- លោកអនុសេនីយ៍ឯក ប៊ុន ពេជ្រណារ័ត្ន ០៥៨៥៩
៣- លោកអនុសេនីយ៍ឯក ឌឹម សំបូរ ១០០១៧
៤- លោកអនុសេនីយ៍ទោ ប្រាក់ សុវណ្ណ ៣៤២៩១
៥- លោកអនុសេនីយ៍ទោ ហុង សារិន ៥៦៤១៣
៦- លោកអនុសេនីយ៍ត្រី ភន សុភ័ណ្ឌ ៥៧៥៥៧
៧- លោកអនុសេនីយ៍ទោ ជា មករា ៥៧៥០៨
៨- លោកអនុសេនីយ៍ទោ ផល រិន ២២២២២

៣៤៧.០៩០៩.៧៨៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ: ៧១៦. ច.ល
...ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ៧ ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

## យើង

នស/រកត/០៨០៩/៧៧៤

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

លោក អ៊ួច អនុត្តរោ

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៩០៤.៧៤៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៩

លេខ: ៧១៥ ច.ល
ចម្លងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុន ចិនកេន

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតក្រុមការងារកំណែទម្រង់រដ្ឋបាលនៅតាមក្រសួង ស្ថាប័ន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៨/៣៤៦ ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីគោលការណ៍រួម នៃការបង្កើតនិងដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេស
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

- បានឃើញអនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៨ ស្តីពីការអនុវត្តប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៩ ស្តីពីការបង្កើត និងដាក់ឱ្យដំណើរការកម្មវិធីកន្សោមអាទិភាព
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៩ ស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

## សម្រេច

**មាត្រា ១.-**

បង្កើតក្រុមការងារកំណែទម្រង់រដ្ឋបាលនៅតាមក្រសួង ស្ថាប័ន ក្នុងគោលដៅសម្របសម្រួលការអនុវត្តកម្មវិធី យុទ្ធសាស្ត្រ និងសកម្មភាពកំណែទម្រង់រដ្ឋបាលនៅក្នុងក្រសួង ស្ថាប័នសាមី តាមការចង្អុលទិសរបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

**មាត្រា ២.-**

ក្រុមការងារកំណែទម្រង់រដ្ឋបាលនៅតាមក្រសួង ស្ថាប័ន ត្រូវស្ថិតនៅក្រោមការដឹកនាំ និងគ្រប់គ្រងរបស់រដ្ឋមន្ត្រី ឬ ប្រធានស្ថាប័នសាមី ។

ក្រុមការងារកំណែទម្រង់រដ្ឋបាលនៅតាមក្រសួង ស្ថាប័នមានសមាសភាពដូចខាងក្រោម :

- រដ្ឋលេខាធិការ ឬ អនុរដ្ឋលេខាធិការ ឬ ឋានៈស្មើក្នុងរចនាសម្ព័ន្ធ ០១ រូប ជាប្រធាន
- អគ្គនាយក/អគ្គនាយករង ឬ អគ្គលេខាធិការ/អគ្គលេខាធិការរង ឬ អគ្គាធិការ/អគ្គាធិការរង ឬ ឋានៈស្មើក្នុងរចនាសម្ព័ន្ធ ០១ រូប ជាសមាជិក
- ប្រធាន/អនុប្រធាននាយកដ្ឋានជំនាញ ឬ ឋានៈស្មើក្នុងរចនាសម្ព័ន្ធ ០១ រូប ជាសមាជិក
- មន្ត្រីជំនាញ ០២ រូប ជាជំនួយការ

**មាត្រា ៣.-**

ក្រុមការងារកំណែទម្រង់រដ្ឋបាលនៅតាមក្រសួង ស្ថាប័ន មានតួនាទី និងភារកិច្ចចម្បងៗដូចខាងក្រោម :

- ទទួលខុសត្រូវចំពោះមុខរដ្ឋមន្ត្រី ឬ ប្រធានស្ថាប័នសាមី ក្នុងការគ្រប់គ្រង និងដឹកនាំគ្រប់ការងារពាក់ព័ន្ធទៅនឹងកម្មវិធី យុទ្ធសាស្ត្រ និងសកម្មភាពកំណែទម្រង់រដ្ឋបាលរបស់ក្រសួង ស្ថាប័ន
- សម្របសម្រួលការងារកំណែទម្រង់រដ្ឋបាលរវាងក្រសួង ស្ថាប័នសាមី ជាមួយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងកំណែទម្រង់តាមវិស័យ

- សម្របសម្រួល និងជំរុញការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងសកម្មភាពកំណែទម្រង់រដ្ឋបាល
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងធ្វើរបាយការណ៍ ស្តីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាល ជូនរដ្ឋមន្ត្រី ឬ ប្រធានស្ថាប័ន និងក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

**មាត្រា ៤.-**

ក្រុមការងារកំណែទម្រង់រដ្ឋបាលនៅតាមក្រសួង ស្ថាប័ន ត្រូវដើរតួនាទីជាក្រុមការងារគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព និងមានភារកិច្ចក្នុងការសម្របសម្រួលការរៀបចំសំណើ ការបង្កើត ការដាក់ឱ្យដំណើរការ ការគ្រប់គ្រង និងតាមដាន ត្រួតពិនិត្យការអនុវត្តកម្មវិធីកន្សោមអាទិភាព ប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ និងទីភ្នាក់ងារប្រតិបត្តិការពិសេស ។

**មាត្រា ៥.-**

ប្រធានក្រុមការងារកំណែទម្រង់រដ្ឋបាលនៅតាមក្រសួង ស្ថាប័ន ត្រូវដើរតួនាទីជាអនុប្រធាន ឬ សមាជិកនៃគណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព ។

សមាជិកក្រុមការងារកំណែទម្រង់រដ្ឋបាលនៅតាមក្រសួង ស្ថាប័នដែលជា អគ្គនាយក / អគ្គនាយករង ឬ អគ្គលេខាធិការ/ អគ្គលេខាធិការរង ឬ អគ្គាធិការ / អគ្គាធិការរង ឬ ឋានៈស្មើក្នុងរចនាសម្ព័ន្ធ ត្រូវដើរតួនាទីជានាយកកម្មវិធីកន្សោមអាទិភាព ។

ក្រុមការងារកំណែទម្រង់រដ្ឋបាលនៅតាមក្រសួង ស្ថាប័ន អាចដើរតួនាទីនៅក្នុងផ្នែកផ្សេងៗទៀត តាមការចាត់តាំងរបស់រដ្ឋមន្ត្រី ឬ ប្រធានស្ថាប័នទាក់ទងទៅនឹងវិស័យកំណែទម្រង់រដ្ឋបាល ។

**មាត្រា ៦.-**

ការតែងតាំងសមាសភាពក្រុមការងារកំណែទម្រង់រដ្ឋបាលនៅតាមក្រសួង ស្ថាប័ន ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល តាមសំណើរបស់រដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័នសាមី ។

**មាត្រា ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សូមមេត្តាចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល**

**សុខ អាន**

**<u>កន្លែងទទួល</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១១៤ . អនក្រ . បក**

# អនុក្រឹត្យ

# ស្តីពី

# ការរៀបចំ និងការប្រព្រឹត្តទៅ

# របស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិអេស្កាប់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៩/០២៦ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៩ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអេស្កាប់
- តាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិអេស្កាប់

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិអេស្កាប់ ហៅកាត់ថា "អគ្គលេខាធិការដ្ឋាន គ.ជ.អ.ស." ។

## ជំពូកទី២
## តួនាទី និងភារកិច្ច

**មាត្រា ២.-**

អគ្គលេខាធិការដ្ឋាន គ.ជ.អ.ស. មានតួនាទី និងភារកិច្ចដូចតទៅ ÷

- ជួយរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពជូនរាជរដ្ឋាភិបាល
- ជួយទំនាក់ទំនងរាល់សកម្មភាពការងារជាមួយគណៈកម្មការសេដ្ឋកិច្ច និងសង្គមកិច្ច សម្រាប់អាស៊ី និងប៉ាស៊ីហ្វិកនៃអង្គការសហប្រជាជាតិ ដោយធ្វើការសម្របសម្រួល និងសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ បណ្តាអង្គការជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍនានា
- សម្របសម្រួល និងធ្វើសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំ និងបញ្ជូនមន្ត្រីរាជរដ្ឋាភិបាលទៅចូលរួមកិច្ចប្រជុំ សន្និសីទ វគ្គបណ្តុះបណ្តាល និងសិក្ខាសាលានានា ដែលរៀបចំ និងសម្របសម្រួលដោយគណៈកម្មការសេដ្ឋកិច្ច សង្គមកិច្ច សម្រាប់អាស៊ី និងប៉ាស៊ីហ្វិកនៃអង្គការសហប្រជាជាតិ
- ផ្តួចផ្តើម និងរៀបចំកិច្ចប្រជុំ សន្និសីទ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលនានានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំដៅចូលរួមអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច
- រៀបចំកម្មវិធីការងារ ពិធីការ របៀបវារៈ និងឯកសារផ្សេងៗ សម្រាប់គ្រប់អង្គប្រជុំ និងពិធីផ្លូវការផ្សេងៗ
- ធានានិរន្តរភាព នៃដំណើរការរដ្ឋបាលប្រចាំថ្ងៃរបស់ គ.ជ.អ.ស.
- ស្រាវជ្រាវវិភាគ និងធ្វើបច្ចុប្បន្នភាពព័ត៌មាន ទិន្នន័យ និងសកម្មភាពរបស់គណៈកម្មការសេដ្ឋកិច្ច សង្គមកិច្ច សម្រាប់អាស៊ី និងប៉ាស៊ីហ្វិកនៃអង្គការសហប្រជាជាតិ ដើម្បីធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល និងផ្សព្វផ្សាយចែករំលែកដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សម្របសម្រួល តាមដាន ជំរុញ វាយតម្លៃ និងត្រួតពិនិត្យរាល់ផែនការសកម្មភាព ការងារគម្រោងអភិវឌ្ឍន៍ និងកិច្ចព្រមព្រៀងនានារវាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងគណៈកម្មការសេដ្ឋកិច្ច សង្គមកិច្ច សម្រាប់អាស៊ី និងប៉ាស៊ីហ្វិកនៃអង្គការសហប្រជាជាតិ និង/ឬ រវាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងបណ្តាប្រទេសជាសមាជិកក្នុងក្របខណ្ឌគណៈកម្មការសេដ្ឋកិច្ច សង្គមកិច្ច សម្រាប់អាស៊ី និងប៉ាស៊ីហ្វិកនៃអង្គការសហប្រជាជាតិ
- រៀបចំរបាយការណ៍ការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនប្រធាន គ.ជ.អ.ស.
- លើកគម្រោងថវិកា ចំណូល និងចំណាយរបស់ គ.ជ.អ.ស.
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាន គ.ជ.អ.ស. ប្រគល់ជូន។

## ជំពូកទី៣
## រចនាសម្ព័ន្ធនិងការគ្រប់គ្រង

**មាត្រា ៣.-**

គ.ជ.អ.ស. មានគណៈកម្មការប្រតិបត្តិមួយសម្រាប់ដឹកនាំការងារប្រចាំថ្ងៃ និងក្រុមការងារថ្នាក់ក្រសួង ស្ថាប័ន។ គណៈកម្មការប្រតិបត្តិមានសមាសភាពដូចខាងក្រោម ÷

- ប្រធាន គ.ជ.អ.ស.
- អនុប្រធាន គ.ជ.អ.ស.
- អគ្គលេខាធិការ គ.ជ.អ.ស.
- អគ្គលេខាធិការរង គ.ជ.អ.ស.។

**មាត្រា ៤.-**

អគ្គលេខាធិការដ្ឋាន គ.ជ.អ.ស. ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប ដែលមានឋានៈស្មើរដ្ឋលេខាធិការ អមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៥.-**

ក្រុមការងារ គ.ជ.អ.ស. ថ្នាក់ក្រសួង ស្ថាប័ន ត្រូវបង្កើតឡើងដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី។ ក្រុមការងារ គ.ជ.អ.ស. ថ្នាក់ក្រសួង ស្ថាប័ន មានតួនាទី និងភារកិច្ចដូចតទៅ ÷

- ធ្វើជាសេនាធិការ និងជាជំនួយការរបស់ គ.ជ.អ.ស.
- រៀបចំផែនការសកម្មភាពសម្រាប់អនុវត្តការងារ គ.ជ.អ.ស. តាមក្រសួង ស្ថាប័ន
- ធ្វើរបាយការណ៍ការងារប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ស្តីពីការអនុវត្តសកម្មភាពការងារ និងកិច្ចសហប្រតិបត្តិការរវាងក្រសួង ស្ថាប័នសាមី និងគណៈកម្មការសេដ្ឋកិច្ច សង្គមកិច្ច សម្រាប់អាស៊ី និងប៉ាស៊ីហ្វិកនៃអង្គការសហប្រជាជាតិ ជូន គ.ជ.អ.ស.។

**មាត្រា ៦.-**

អគ្គលេខាធិការដ្ឋាន គ.ជ.អ.ស.មានរចនាសម្ព័ន្ធដូចតទៅ ÷

- នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- នាយកដ្ឋានទំនាក់ទំនងអន្តរស្ថាប័នជាតិ និងអន្តរជាតិ
- នាយកដ្ឋានផែនការ ស្រាវជ្រាវ អភិវឌ្ឍ និងបណ្តុះបណ្តាល
- នាយកដ្ឋានត្រួតពិនិត្យ វាយតម្លៃ និងគ្រប់គ្រងទិន្នន័យ។

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន គ.ជ.អ.ស. ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៧.-**

នាយកដ្ឋាននីមួយៗដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។ នាយកដ្ឋាននីមួយៗមានការិយាល័យចំណុះមួយចំនួនតាមការចាំបាច់។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាននីមួយៗត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

ប្រធាននាយកដ្ឋានត្រូវតែងតាំងដោយអនុក្រឹត្យ។ អនុប្រធាននាយកដ្ឋាន និងថ្នាក់ការិយាល័យត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា ៨.-**

អគ្គលេខាធិការដ្ឋាន គ.ជ.អ.ស. មានមន្ត្រីបម្រើការមកពីក្របខណ្ឌមុខងារសាធារណៈ និងអាចជាមន្ត្រីជាប់កិច្ចសន្យាតាមការចាំបាច់ ។

## ជំពូកទី៤
## តួនាទីនិងភារកិច្ចរបស់នាយកដ្ឋាននីមួយៗ

**មាត្រា ៩.-**

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុមានតួនាទី និងភារកិច្ចដូចតទៅ ÷

- ទទួលខុសត្រូវលើសេវាកម្មទូទៅក្នុងផ្នែករដ្ឋបាល និងសម្របសម្រួលការងាររដ្ឋបាល
- ទទួលខុសត្រូវលើលិខិត ឯកសារ លិខិតបទដ្ឋាននានា និងតម្កល់ឯកសារ
- គ្រប់គ្រងមន្ត្រីរាជការ បុគ្គលិក និងការងារអភិវឌ្ឍធនធានមនុស្សក្នុងអគ្គលេខាធិការដ្ឋាន
- ទទួលបន្ទុករៀបចំកិច្ចប្រជុំ សិក្ខាសាលា និងធ្វើរបាយការណ៍ ឬកំណត់ហេតុពីសកម្មភាពការងារ
- រៀបចំគម្រោងថវិកា សម្ភារៈបរិក្ខារ និងមធ្យោបាយនានាប្រចាំឆ្នាំរបស់ គ.ជ.អ.ស.
- រៀបចំឯកសារពាក់ព័ន្ធប្រាក់បៀវត្ស និងស្នើប្រាក់ឧបត្ថម្ភផ្សេងៗជូនមន្ត្រីរាជការ និងបុគ្គលិក
- គ្រប់គ្រង និងថែទាំអចលនទ្រព្យ និងចលនទ្រព្យ
- លើកគម្រោងជួសជុល ផ្គត់ផ្គង់ និងថែទាំអចលនទ្រព្យ និងចលនទ្រព្យ
- ប្រតិបត្តិថវិកាទៅតាមគោលការណ៍លទ្ធកម្ម និងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- ធ្វើរបាយការណ៍ការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនអគ្គលេខាធិការ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលអគ្គលេខាធិការប្រគល់ជូន។

**មាត្រា ១០.-**

នាយកដ្ឋានទំនាក់ទំនងអន្តរស្ថាប័នជាតិ និងអន្តរជាតិមានតួនាទី និងភារកិច្ចដូចតទៅ ÷

- រៀបចំប្រព័ន្ធទំនាក់ទំនង និងសហការជាមួយក្រសួង ស្ថាប័ន ដែលជាសមាជិក គ.ជ.អ.ស. សង្គមស៊ីវិល ផ្នែកឯកជន អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍ ដើម្បីផ្លាស់ប្តូរបទពិសោធ ទិន្នន័យ និងព័ត៌មានក្នុងក្របខណ្ឌ គ.ជ.អ.ស.

- ស្វែងរកដៃគូផ្តល់ជំនួយផ្នែកបច្ចេកទេស ហិរញ្ញប្បទាន ដែលគាំទ្រដល់កិច្ចដំណើរការការងារ គ.ជ.អ.ស.
- តាមដាន និងត្រួតពិនិត្យរាល់គម្រោងជំនួយបច្ចេកទេសរបស់ដៃគូអភិវឌ្ឍជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងក្របខណ្ឌ គ.ជ.អ.ស.
- រៀបចំការផ្លាស់ប្តូរបទពិសោធ មេរៀន និងការអនុវត្តគម្រោងជាមួយដៃគូអភិវឌ្ឍ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងក្របខណ្ឌ គ.ជ.អ.ស.
- ធ្វើទំនាក់ទំនងជាមួយនាយកដ្ឋានជំនាញ ផ្នែកជំនាញ និងអ្នកជំនាញការរបស់គណៈកម្មការសេដ្ឋកិច្ច សង្គមកិច្ច សម្រាប់អាស៊ី និងប៉ាស៊ីហ្វិកនៃអង្គការសហប្រជាជាតិ ដើម្បីផ្តល់ជំនួយទីប្រឹក្សាបច្ចេកទេសដល់ គ.ជ.អ.ស.
- រៀបចំ និងផ្តល់បទបង្ហាញនានារបស់ គ.ជ.អ.ស. ដល់ដៃគូអភិវឌ្ឍ និងអង្គការអន្តរជាតិ
- ធ្វើរបាយការណ៍ការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនអគ្គលេខាធិការ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលអគ្គលេខាធិការប្រគល់ជូន។

**មាត្រា ១១.-**

នាយកដ្ឋានផែនការ ស្រាវជ្រាវ អភិវឌ្ឍ និងបណ្តុះបណ្តាលមានតួនាទី និងភារកិច្ចដូចតទៅ ÷

- រៀបចំផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពនិងទស្សនទាន ដើម្បីសម្រេចបាននូវគោលដៅរួមរបស់ គ.ជ.អ.ស.
- រៀបចំផែនការ និងកម្មវិធីបណ្តុះបណ្តាល សិក្សា និងវាយតម្លៃពីជំនាញ ដែលត្រូវការចាំបាច់ក្នុងការងារបណ្តុះបណ្តាលមន្ត្រីរាជការ និងគ្រូបង្គោលនៅតាមក្រសួង ស្ថាប័ន ដែលជាសមាជិក គ.ជ.អ.ស.
- រៀបចំកម្មវិធី និងវគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រីគ្រប់គ្រង និងមន្ត្រីជំនាញរបស់អគ្គលេខាធិការដ្ឋាន
- សិក្សា សម្របសម្រួល និងចងក្រងទិន្នន័យផ្សេងៗ ផ្នែកជំនួយបច្ចេកទេសពាក់ព័ន្ធនឹងការបណ្តុះបណ្តាល ដើម្បីរៀបចំគោលនយោបាយ សំដៅធានាប្រសិទ្ធភាព និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង
- ស្រាវជ្រាវ វិភាគ និងធ្វើបច្ចុប្បន្នភាពព័ត៌មាន ទិន្នន័យ និងសកម្មភាពរបស់គណៈកម្មការសេដ្ឋកិច្ច សង្គមកិច្ច សម្រាប់អាស៊ី និងប៉ាស៊ីហ្វិកនៃអង្គការសហប្រជាជាតិ ដើម្បីធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល និងផ្សព្វផ្សាយ ចែករំលែកដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សម្របសម្រួល និងធ្វើសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំ និងបញ្ជូនមន្ត្រីរាជរដ្ឋាភិបាលទៅចូលរួមប្រជុំ សន្និសីទ វគ្គបណ្តុះបណ្តាល និងសិក្ខាសាលានានា ដែលរៀបចំ និងសម្របសម្រួលដោយគណៈកម្មការសេដ្ឋកិច្ច សង្គមកិច្ច សម្រាប់អាស៊ី និងប៉ាស៊ីហ្វិកនៃអង្គការសហប្រជាជាតិ
- ផ្តួចផ្តើម និងរៀបចំកិច្ចប្រជុំ សន្និសីទ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលនានានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំដៅចូលរួមការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច

- សម្របសម្រួល និងសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ អង្គការជាតិ អន្តរជាតិ ក្នុងការលើកគម្រោង គៀងគរកមធ្យោបាយ និងធនធាន ដើម្បីរួមចំណែកក្នុងការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច ក្នុងគោលបំណងសំដៅកាត់បន្ថយភាពក្រីក្រ អភិវឌ្ឍធនធានមនុស្ស និងលើកកម្ពស់អភិបាលកិច្ចល្អ
- ធ្វើរបាយការណ៍ការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនអគ្គលេខាធិការ
- អនុវត្តភារកិច្ចផ្សេងទៀត.ដែលអគ្គលេខាធិការប្រគល់ជូន។

**មាត្រា ១២.-**

នាយកដ្ឋានត្រួតពិនិត្យ វាយតម្លៃ និងគ្រប់គ្រងទិន្នន័យមានតួនាទី និងភារកិច្ចដូចតទៅ ÷

- ប្រមូលផ្តុំឯកសារ ស្រង់ព័ត៌មាន និងចងក្រងទិន្នន័យ ឯកសារបច្ចេកទេស ក្រោមកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមូលដ្ឋាន ក្រសួង ស្ថាប័ន និងអង្គការជាតិ អន្តរជាតិដែលពាក់ព័ន្ធ
- រៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ គ.ជ.អ.ស. ប្រកបដោយប្រសិទ្ធភាពខ្ពស់
- ត្រួតពិនិត្យ និងវាយតម្លៃលើសមិទ្ធផលនៃការអនុវត្តការងារ ដែលជាភារកិច្ចរបស់បណ្តាអង្គភាពនៅក្នុងបន្ទុករបស់ គ.ជ.អ.ស.
- សម្របសម្រួល តាមដាន ជំរុញ វាយតម្លៃ និងត្រួតពិនិត្យរាល់ផែនការសកម្មភាព ការងារគម្រោងអភិវឌ្ឍន៍ និងកិច្ចព្រមព្រៀងនានារវាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងគណៈកម្មការសេដ្ឋកិច្ច សង្គមកិច្ចសម្រាប់អាស៊ី និងប៉ាស៊ីហ្វិកនៃអង្គការសហប្រជាជាតិ និង/ឬ រវាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងបណ្តាប្រទេសជាសមាជិកក្នុងក្របខណ្ឌគណៈកម្មការសេដ្ឋកិច្ចសង្គមកិច្ចសម្រាប់អាស៊ី និងប៉ាស៊ីហ្វិកនៃអង្គការសហប្រជាជាតិ
- បង្កើត និងគ្រប់គ្រងគេហទំព័ររបស់ គ.ជ.អ.ស.
- ធ្វើរបាយការណ៍ការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនអគ្គលេខាធិការ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលអគ្គលេខាធិការប្រគល់ជូន។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា ១៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិអេស្កាប់ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០៩*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា សូមហត្ថលេខា
**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស**
**និងជាប្រធានគណៈកម្មាធិការជាតិអេស្កាប់**

**លី ធុជ**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១៤*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ.១១៤.... អនក្រ.បក ចុះថ្ងៃទី២៩. ខែ.កក្កដា.ឆ្នាំ ២០០៩**
**អង្គការលេខរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិអេស្កាប់**



# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៖ ១១៥ អនក្រ-បក

## អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៩
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក. ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
